វគ្គទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោរពផ្ញើរជូនកម្មវិធីកូនខ្មែរពិត

ជាកិច្ចចាប់ផ្តើមខ្ញុំសូមគោរពនិងជំរាបសួរ ប្រិយមិត្តអ្នកស្តាប់ទាំងអស់ពីចំងាយ លោកអ្នកសុខសប្បាយជាទេ? ខ្ញុំសូមលំអោនកាយអភ័យទោសនូវរាល់កំហុសឆ្គងទាំងប៉ុន្មានដែលបានកើតមានឡើងក្នុងកម្មវិធីនេះ ។ ខ្ញុំមានការសោកស្តាយណាស់ដែលខ្ញុំមិនបានរៀបចំនូវអត្ថបទទី៣ របស់ខ្ញុំអោយបានត្រឹមត្រូវជាពិសេសគឺសូមការអធ្យាស្រ័យ យោគយល់ពីសំណាក់ ពុកម៉ែ បង ប្អូន និងអ្នកនាងពិធីការនី ដែលខ្ញុំបានធ្វើអោយអ្នកនាងមានការលំបាកក្នុងការរៀបចំ ។ វាជាកំហុសដោយអចេតនារបស់ខ្ញុំដែលមានការធ្វេសប្រហែសហើយធ្វើអោយរំខាននូវអារម្មណ៏របស់អ្នកគ្រប់គ្នា ។ ខ្ញុំសន្យាថាខ្ញុំមិនធ្វើអោយអ្នកលំបាកទៀតទេ ។

នេះជាលិខិតលើកទី៤ហើយក៏ជាលិខិតបញ្ចប់នូវប្រវត្តិរបស់ខ្ញុំ ។ តាមពិតទៅខ្ញុំមិនមានបំណងអូសបន្លាយនៅពេលវេលាដ៏មានតំលៃរបស់អ្នកគ្រប់គ្នាអោយរង់ចាំចង់ដឹងថា **ខ្ញុំជាអ្នកណា** នោះទេ ។ តែជាការពិតខ្ញុំឆ្លៀតពេលទំនេរបានតែបន្តិចបន្តួចពីការងារដើម្បីសរសេរនូវអត្ថបទទាំងនេះ ។ មែនហើយវាគួរតែល្មមសមគួរដែលខ្ញុំគួរតែរៀបចំអោយបានលឿនដើម្បីបញ្ចប់នូវអត្ថបទរបស់ខ្ញុំ ។សូមអ្នកស្តាប់កុំធុញទ្រាន់ណា៎ ព្រោះនេះជាពេលវេលាដែលខ្ញុំនិងបញ្ចប់វាហើយ ។

បន្ទាប់ពីលោកតាលោកយាយទទួលអនិច្ចកម្មអស់ទៅ ខ្ញុំបាត់បង់គ្រប់បែបយ៉ាងហើយខ្ញុំបានក្លាយជាក្មេងកំព្រាគ្មានអាណាព្យាបាលទៀតឡើយ ។ ដូចខ្ញុំជំរាបពីវគ្គ៣ គឺខ្ញុំត្រូវបានលាមីង លាបង លាប្អូនធ្វើដំណើរផ្សងព្រេង រសាត់អណ្តែត ក្នុងគោលបំណងស្វែងរកអនាគតនាផ្លូវថ្មីមួយ ។ ខ្ញុំមានកង់ចាស់មួយ មានសំលៀកបំពាក់បន្តិចបន្តួច ធ្វើដំណើរដោយជិះកង់ប្រមាណ ជិតមួយព្រឹក ដើម្បីសំដៅមកទីក្រុង រកការងារធ្វើ ។ ពីតូចខ្ញុំកំព្រាដែរ តែនៅមានតា មានយាយ តែពេលនេះខ្ញុំត្រូវក្លាយជាជនអនាថាដែលគ្មានអ្នកណាជាកំលាំងចិត្តទៀតឡើយ ។ ខ្ញុំមានប្រាក់បន្តិចបន្តួចជាប់តាមខ្លួនហើយព្យាយាមមករកជួលផ្ទះគេនៅតែឈ្នួលផ្ទះថ្លៃណាស់ខ្ញុំគ្មានសម្ថភាពជួលទេ ដូច្នេះហើយក្នុងថ្ងៃដំបូងខ្ញុំបានសំរាកនៅក្បែររបងវត្តមួយ ។ នេះគឺជារូបខ្ញុំ ចុះប្រសិនបើអ្នកវិញតើអ្នកសំរាន្តលក់ទេ? អ្នកធ្វើដូចខ្ញុំទេ? អ្នកពិតជាធ្វើព្រោះយើងគ្មានជំរើស ។ មួយយប់ទល់ភ្លឺ ខ្ញុំគ្មានអារម្មហ៏ងងុយសោះឡើយ គឺខ្ញុំបានត្រឹមសំរក់ទឹកភ្នែកដេកលើក្រម៉ាអាណិតខ្លួនឯងដែលមានសារជាតិជាមនុស្សដែរ តែមានកម្មវិជ្ជវាតខុសគេទៅវិញ ។

ព្រលឹមស្រាង៧ព្រះសង្ឃ និងសិស្សលោកបានបោសសំអាតទីធ្លាវត្ត ហើយក៏បានឃើញខ្ញុំលោកមានការ

អាណិតអាសូរក៏ផ្តល់អោយខ្ញុំបាននូវចំណីអាហារទទួលទានហើយលោកក៏បានអោយមកខ្ញុំនូវអាហារក្រៀមមួយចំនួនទៀតសំរាប់ទុកហូបតាមផ្លូវខ្ញុំបានសំពះអព្រះគុណដល់ព្រះសង្ឃដោយមានទឹកភ្នែករលីងរលោងនិងក្រាបសំពះលាលោកធ្វើដំណើរត្រាច់ចរបន្តទៀត ។

ជិះកង់ដើររកការងារធ្វើវាមានការលំបាកខ្លាំងណាស់ តែខ្ញុំនៅតែខំព្យាយាម ។ ប៉ុន្តែវាមិនមែនងាយដូចជាយើងគិតនោះទេ ។ខ្ញុំរកការងារមិនបានធ្វើសោះហើយខ្ញុំក៏បានសំរេចចិត្តសុំវត្តអារាមដើម្បីបានស្នាក់នៅបណ្តោះអាសន្ន និងបានអាហារខ្លះសំរាប់ហូបចុក ។

ដោយសារតែអស់លទ្ធិភាពក្នុងការរកការងារធ្វើខ្ញុំក៏បានសំរេចចិត្តទៅសុំអ៊ំស្រីម្នាក់ដែលគាត់បានស្គាល់យាយរបស់ខ្ញុំ ។ គាត់ក៏អនុញ្ញាតិអោយខ្ញុំបានជ្រកកោនជាមួយ ។ផ្ទះគាត់មិនជាធំទេហើយគាត់មានអ្នកសុំស្នាក់នៅដូចជាខ្ញុំច្រើននាក់ទៀតដូច្នេះហើយខ្ញុំបានត្រូវម្ចាស់ផ្ទះអោយសំរាកក្បែរចង្រ្កានបាយដូចការពីខ្ញុំនៅក្មេងនៅគីឡូម៉ែត្រលេខប្រាំពីដែល ។វាធ្វើអោយខ្ញុំរិតតែនឹកឃើញនូវអនុស្សាវរីយ៍ដ៏ជូចត់ដែលខ្ញុំជួបកន្លងមក ។ខ្ញុំតែងតែធ្វើគ្រប់កិច្ចការដែលម្ចាស់ផ្ទះមានហើយឆ្លៀតពេលទៅរកដាក់ពាក្យចូលរៀនបន្ត ។ តែដាក់ពាក្យកន្លែងណាក៏មិនជាប់សាលាណាក៏មិនបាន ។ និយាយអោយចំទៅគឺខ្ញុំខ្វះថវិការដូច្នេះក៏ចេះតែផ្សងព្រេងតាមកម្មវាសនាទៅ ។មួយរយះពេលវែងខ្ញុំបានជួបសំណាងល្អគឺខ្ញុំបានដាក់ពាក្យជាប់បានចូលរៀនផ្នែកពេទ្យបឋម ។ ខ្ញុំសប្បាយចិត្តស្ទើរតែហោះផុតពីដី ខ្ញុំព្យាយាមរៀនផងជួយធ្វើការគេផងហើយម្ចាស់ផ្ទះក៏បានអោយប្រាក់បន្តិចបន្តួចសំរាប់ទិញសំភារះសិក្សា ។

ប៉ុន្តែដោយសារតែកន្លែងខ្ញុំស្នាក់នៅឆ្ងាយពីសាលា ហើយខ្ញុំត្រូវងើបជិះកង់ទៅតាំងពីព្រលឹមរួចត្រឡប់មកវិញម៉ោងប្រហែល៨ យប់ ហើយនិងត្រូវជួយរៀបចំរបស់របរដែលម្ចាស់ផ្ទះគេលក់ដូទំរាំបានទទួលទានបាយម៉ោងស្ទើរ១២ទៅហើយ ។ ដូច្នោះខ្ញុំមានពេលវេលាតិចតួចពេកសំរាប់រៀនសូត្រ ខ្ញុំក៏សូមការអនុញ្ញាតិពីម្ចាស់ផ្ទះដើម្បីចាកចេញរកកន្លែងថ្មី ។ ខ្ញុំក៏បានមកសុំជ្រកកោននូវផ្ទះមួយទៀតដែលបានចំងាយ៤គីឡូម៉ែត្រពីសាលារៀនខ្ញុំនៅតែជិះកង់ទៅរៀន និងជួយការងារគេដដែលដើម្បីដូរអាហារនិងការស្នាក់នៅ ។ ម្ចាស់ផ្ទះថ្មីមានមុខរបរជាអ្នកលក់ឈើ ដូច្នេះខ្ញុំត្រូវឆ្លៀតពេលវេលាពីសាលារៀនមកជួយ លី សែង ឈើ  រៀបចំ ទុកដាក់ ហើយបើសាលាសំរាកយូ ខ្ញុំត្រូវធ្វើដំណើរទៅកាន់ខេត្តកោះកុងដើម្បីជួយទំលាក់ឈើ និងធ្វើសព្វកិច្ចការដែលគេប្រើ ។ ទោះបីជាហត់នឿយយ៉ាងណាខ្ញុំមិនហ៊ានសំរាកទេព្រោះខ្លាចម្ចាស់ផ្ទះគេស្តីអោយ ។ ខ្ញុំតែងតែដេកបង្ហូរទឹកភ្នែកហើយនិងឈឺចាប់កាន់តែខ្លាំងឡើង១ ធ្វើអោយខ្ញុំកាន់តែយល់

ពីភាពលំបាកវេទនារបស់អ្នកក្រ ។ ខ្ញុំចង់ជំរាបថាខ្ញុំពិតជាយល់យ៉ាងច្បាស់ចំពោះ ជីវិតអ្នកដែលរស់នៅជ្រកកោនជាមួយគេខ្ញុំយល់ពីទំហំចិត្តអ្នក ខ្ញុំដឹងថាអ្នកពិតជាត្រូវការអ្វី? អ្នកចង់បានអ្វី ? អ្នកខ្លាចចិត្តគេប៉ុណ្ណា ?

ប្រសិនបើអ្នក កំពុងតែជួបបញ្ហាបែបនេះសូមអ្នកតស៊ូឡើងណា អ្នកកុំចុះចាញ់និងវាសនា អ្នកត្រូវតែព្យាយាមអត់ធ្មត់ដើម្បីអនាគតរបស់អ្នក ។ ហើយខ្ញុំក៏យល់ដែលថាលោកអ្នកដែលជាម្ចាស់ផ្ទះទាំងអស់គឺតែងតែមានចិត្តអាណិតស្រលាញ់ហើយទើបផ្តល់នូវកន្លែង ជ្រកកោន ផ្តល់នូវអាហារ ផ្តល់នូវការងារអោយធ្វើ តែ សូមអ្នកមេត្តាយល់ដល់ពួកគេផង អ្នកគួរតែផ្តល់ឱកាស ខ្លះសំរាប់ពួកគេ បានសំរាក ។ លោកអ្នកមួយចំនួនបានដៀលត្មិះមើលងាយមើលថោក មិនអោយតំលៃមនុស្សដូចគ្នា បាយរបស់អ្នកមួយពេលវាពិតជាមានតំលៃណាស់ ។ តែអ្នកគួរតែយល់ថាពួកគេបានបំរើអ្នកពួកគេមិនហ៊ានប្រកែកនូវអ្វីដែលអ្នកប្រើទេ ទោះជាអស់កំលាំងឬក៏យប់ជ្រៅយ៉ាងណាក៏ដោយ ។ ឱ ! អ្នកក្រទាំងឡាយអើយ អ្នកឈប់យំទៅ អ្នកឈប់ បង្ហូរទឹកភ្នែកទៀតទៅ អ្នកតស៊ូឡើងធ្វើម្តេចបើយើងត្រូវបានទេវតាចាយ៉ាងនេះទៅហើយ គឺមានតែយើងត្រូវតែប្រឹងធ្វើបន្តទៀតដើម្បី ពុក ដើម្បីម៉ែ បង ប្អូនយើងដែលក្រពះរបស់ពួកគាត់ កំពុងតែ រង់ចាំជំនួយរបស់អ្នក ។ យើងត្រូវតែនាំគ្នាធ្វើដើម្បីអ្នកមានគុណ ដើម្បីមនុស្សជាទីស្រលាញ់របស់យើង ។ ខ្ញុំគ្មានបំណងរមិលគុណចំពោះលោកអ្នកដែលផ្តល់កន្លែងជ្រកកោនចំពោះអ្នកក្រទេតាមពិតទៅលោកជាមនុស្សដែលបានផ្តល់ឱកាសអោយជនក្រីក្រមានការងារធ្វើ តែខ្ញុំគ្រាន់តែសូមអង្វរចិត្តអ្នកសូមអ្នកគិតថាគេ ក៏ដូចជាកូនអ្នកដែរ ដូច្នេះអ្នកផ្តល់ឱកាសខ្លះសំរាប់ពួកគេផង ។ អោយខ្ញុំសូមទោសផងណាដែលធ្វើអោយអ្នកទាំងអស់គ្នាមិនសប្បាយចិត្ត ។

ខ្ញុំនឹងនិយាយរឿងរបស់ខ្ញុំបន្តទៀត ។ ដោយសារការសិក្សារបស់ខ្ញុំកាន់តែច្រើនឡើងហើយមិនសូវមានពេលវេលាសំរាប់ជួយពួកគាត់ខ្ញុំក៏សំរេចចិត្តសូមលាម្ចាស់ផ្ទះទី២ ដើម្បីមកសុំសាលាពេទ្យបានស្នាក់នៅបន្ត ។ ខ្ញុំស្នាក់នៅក្នុងបន្ទប់ជាមួយមិត្តរួមសាលា ៥ នាក់ហើយពួកគេក៏ជាកូនអ្នកក្រដែរតែ គេនៅមានម៉ែឪ ទំនុងបំរុង ។

ឆ្លៀតពេលទំនេរខ្លះ។ពីការរៀនសូត្រខ្ញុំបានជួលស៊ីក្លូគេធាក់ដើម្បីសន្សំប្រាក់ទុកទិញសំភារះដែលត្រូវការហើយពេលយប់ខ្ញុំបានសុំគេធ្វើការក្នុងភោជនីដ្ឋានមួយ តែខ្ញុំធ្វើបានតែ៣ថ្ងៃប៉ុណ្ណោះក្នុងមួយអាទិត្យ ។ ហើយក្នុងមួយខែខ្ញុំទទួលបានប្រាក់កំរៃបន្តិចបន្តួច ប៉ុន្តែខ្ញុំសប្បាយចិត្តណាស់ ។ខ្ញុំសន្សំបានប្រាក់រាងច្រើន

បន្តិចតែមិនហ៊ានចាយទេ ។ ហេតុអ្វីបានជាខ្ញុំសន្សំប្រាក់បាន? ពីព្រោះពេលដែលសាលាចាត់តាំងអោយសិស្សចុះស្តា គឺខ្ញុំបានជួយមើល និង ជួយថែទាំអ្នកជំងឺដោយយកទុកដាក់ ដូច្នេះហើយពួកគាត់មានការអាណិតអាសូរក៏អោយប្រាក់ខ្ញុំខ្លះសំរាប់ទិញបាយហូប ។ អ្នកខ្លះគេមិនជឿខ្ញុំ ទេថាខ្ញុំជាកូនកំព្រាពីព្រោះខ្ញុំបានរៀនចប់ពេទ្យបឋម ។ បន្ទាប់ពីរៀនចំក្រសួងបានដាក់គោលដៅ ហើយបើនិយាយអោយស្រួលស្តាប់គេហៅថា ប៉ុស ។ មិត្តភក្តិរបស់ខ្ញុំមួយចំនួនរបស់ខ្ញុំគេបាន ប៉ុសនៅជិត១ ហើយជាកន្លែងងាយស្រួលទៀតផង ។ចំណែកខ្ញុំបែរជាក្រសួងដាក់អោយទៅឆ្ងាយ ប្រមាណជិត១៥០គីឡូម៉ែត្រពីក្រុងដោយក្នុងពេលនោះទទួលបានប្រាក់បៀវត្សតែ ២៨០០០រៀលប៉ុណ្ណោះ ។ ខ្ញុំធ្លាក់ថ្លើមក្តុកគ្មានចំឡើយអ្វីតបទេ ។ ខ្ញុំដេកគិតមួយយប់ក៏សំរេចចិត្តមិនទៅពីព្រោះប្រាក់ខែដែលទទួលបានវាមិនរួចថ្លៃអាហារនិងជួលផ្ទះស្នាក់នៅឡើយហើយខ្ញុំសោកស្តាយណាស់ដែលខ្ញុំបានព្យាយាមរៀនសូត្រតាំងពីតូចត្រូវបានរលាយបាត់ដោយសារតែខ្ញុំគ្មានប្រាក់ ដើម្បីតស៊ូទៀត ។ ពេលនេះខ្ញុំកាន់តែ តែលតោល កាន់តែលំបាកហើយប្រាក់សន្សំក៏កាន់តែខើចទៅ១ ។ ខ្ញុំត្រូវជិះកង់របស់ខ្ញុំដើររកការងារធ្វើជាថ្មី ។

ខ្ញុំបានសុំផ្ទះមិត្តភ័ក្តសំរាកពេលយប់ហើយពេលថ្ងៃត្រូវទៅធាក់ស៊ីក្លូ និងឆ្លៀតពេលដើររកកាងារធ្វើ ។ ខ្ញុំប្រឹងប្រែងខ្លាំងណាស់គ្មានពេលសំរាកទេ មានពេលដែលខ្ញុំរកប្រាក់មិនបានខ្ញុំសំរេចចិត្តចូលសុំបាយព្រះសង្ឃទទួលទាន ។ ថ្ងៃខ្លះខ្ញុំជិះស៊ីក្លូដោយមិនដឹងថាមានភ្លៀងធ្លាក់ស្រោចស្រប់លើរាង្គកាយរបស់ខ្ញុំទេ ដោយអារម្មណ៏របស់ខ្ញុំ កំពុងតែជោគជាំទៅដោយការឈឺចាប់ និងក្តីវេទនារកទីបំផុតគ្មាន ។ ខ្ញុំតែងតែយំរាល់ពេលដែលខ្ញុំទទួលទានបាយ គឺខ្ញុំហូបតែបាយកញ្ចប់តែម្នាក់ឯងរហូត គ្មានអ្នកណាគេមើលមុខខ្ញុំទេ ។ ខ្ញុំនឹកយាយណាស់ ខ្ញុំនឹកតាណាស់ ខ្ញុំនឹកបងប្អូនខ្ញុំណាស់ហើយពេលខ្លះខ្ញុំចង់ស្លាប់ដើម្បីអោយផុតទុក្ខទោសទាំងអស់ ។ តែសតិសម្បជញ្ញៈ បានរំលឹកខ្ញុំអោយតស៊ូជាថ្មី ហើយកុំចុះចាញ់និងព្រហ្មលិខិត ។ពេលដែលនឹកឃើញបែបនេះខ្ញុំតែងតែយកក្រមាដែលខ្ញុំបង់កជូតទឹកភ្នែកហើយទាញកង់ជិះដើររកការងារធ្វើជាបន្តទៀត ។ មែនវាសនាមនុស្សមិនមែនសុទ្ធតែអាក្រក់ទាំងអស់នោះទេយ៉ាងណាម៉េញ ដូចជារូបខ្ញុំជាដើម ការស្វះស្វែងរបស់ខ្ញុំក៏បានសំរេចដូចបំណង ។ ខ្ញុំបានសុំកន្លែងមួយធ្វើការម្ចាស់គេសួរថា ឯងចង់ធ្វើការអី? ខ្ញុំឆ្លើយថាអ្វីក៏ខ្ញុំធ្វើដែរអោយតែអ្នកផ្តល់អោយ គាត់សួរទៀតថាឯងចង់បានប្រាក់ខែប៉ុន្មាន?

ខ្ញុំឆ្លើយថាខ្ញុំសូមតែអាហារបីពេលនិងការស្នាក់នៅប៉ុណ្ណោះព្រោះខ្ញុំជាកូនកំព្រាគ្មានឪពុកម្តាយទេខ្ញុំគ្មាន

កន្លែងស្នាក់នៅទេ ។ គាត់ហួសចិត្តនិងសំដីខ្ញុំហើយក៏អនុញ្ញាតិអោយខ្ញុំ បានធ្វើជាអ្នកលាងចាន លាងឆ្នាំង លាងបង្គន់ និងបោសសំអាតគ្រប់ទីកន្លែង ។ ពេលយប់ខ្ញុំបានដេកនៅក្នុងឃ្លាំងដាក់ទំនិញហើយពេលខ្លះដេកនៅរោងដាក់ឡានតែយ៉ាងណាក៏ខ្ញុំនៅតែសប្បាយចិត្តនិងការងារ ។ ម្ចាស់អាជីវកម្មគាត់ផ្តល់ប្រាក់ខែអោយខ្ញុំ១៥ដុល្លាក្នុង១ខែ ។ នេះជាលើកទី១ហើយដែលខ្ញុំទទួលបាននូវប្រាក់ខែខ្ពស់បែបនេះ ខ្ញុំខិតខំធ្វើការងារខ្លាំងណាស់មិនហ៊ានសំរាកទេ ។ ធ្វើការទីនោះបានរយះពេលបីខែ ខ្ញុំត្រូវបានម្ចាស់អាជីវកម្មអោយខ្ញុំឈប់ធ្វើជាអ្នកលាងចាន ហើយក៏អោយខ្ញុំធ្វើជាអ្នកទទួលខុសលើផ្នែកតូចមួយនៅខាងក្រោយ ហើយប្រាក់ខែរបស់ខ្ញុំបានឡើងដល់៨០ដុល្លា ។

ខ្ញុំសូមជំរាបថាកន្លែងដែលខ្ញុំធ្វើការពេលនោះឥឡូវគឺជាផ្សារដ៏ទំនើបមួយក្នុងទីក្រុងភ្នំពេញ ។ ខ្ញុំព្យាយាមធ្វើការរិតតែខ្លាំង ហើយធ្វើការបាន៦ខែបន្ទាប់លោកថៅកែ ក៏បានអោយខ្ញុំឡើងមកគ្រប់គ្រងទូទៅ ខ្ញុំកាន់តែមានឳកាសសន្សំបានប្រាក់ច្រើន ហើយប្រាក់ខែក៏កាន់តែខ្ពស់គឺឡើងរហូតដល់១៥០ដុល្លា ។ អ្នកដឹងទេថាអារម្មណ៏របស់ខ្ញុំពេលនោះយ៉ាងណា? មិនបាច់ប្រាប់ក៏អ្នកយល់ដែរ ខ្ញុំបានលក់កង់របស់ខ្ញុំ ហើយយកប្រាក់ដែលសន្សំបាន ទិញបានម៉ូតូមួយគ្រឿង ។ ខ្ញុំចាប់ផ្តើមមានមិត្តភក្តិគេរាប់រក ។ ខ្ញុំគិតតែខំប្រឹងធ្វើការដោយសប្បាយរីករាយ ហើយនិងបានរៀនសូត្រនូវ ភាសារអង់គ្លេសទៀត ខ្ញុំមិនដែលនឹកឃើញទេថាថ្ងៃខាងមុខនិងមានរឿងអ្វីកើតឡើង ។តែលោកអ្នកជឿចុះ សប្បាយនិងទុក្ខរមែងតែងតែដើរទន្ទឹមគ្នា ហើយអ្នកត្រូវគិតថាមនុស្សក្នុងលោកមិនមែនសុទ្ធតែស្រលាញ់យើងនិងចង់អោយយើងល្អទាំងអស់នោះទេ ។

ខ្ញុំត្រូវមានបញ្ហាដោយសារតែរឿងរ៉ាវដែលពាក់ពន្ធ័និងសាច់ញាតិរបស់ថៅកែ ។ខ្ញុំមិនចង់រៀបរាប់ទេគ្រាន់តែចង់បញ្ជាក់ថាខ្ញុំបានដើរចេញពីព្រោះខ្ញុំមិនចង់អោយគ្រួសារគេមានបញ្ហាដោយសារខ្ញុំទេ ។ ថៅកែស្រី និង ថៅកែ ប្រុសគាត់មិនចង់អោយខ្ញុំចាកចេញទេតែខ្ញុំបានតាំងចិត្តរួចហើយថាត្រូវតែទៅ ។ ខ្ញុំសំពះលាគាត់និង អគុណទាំងទឹកភ្នែកហូរហាម ។ ខ្ញុំរៀបចំបង្វិចខោអាវ ដាក់លើម៉ូតូ ហើយបើកទាំងទឹកភ្នែកហូរសស្រាក់ដោយការសោកស្តាយនៅការងាររបស់ខ្ញុំ ។

ពេលនោះហើយដែលខ្ញុំក្លាយជាមនុស្សចេះដើរលេង ចេះផឹកស្រាដែលពីមុនមកខ្ញុំមិនធ្លាប់ទាល់តែសោះ ខ្ញុំពិបាកចិត្ត ខ្ញុំនឹកយាយ ខ្ញុំនឹកតាប្រសិនបើគាត់នៅរស់គាត់ប្រហែលជាជួយលួងលោមអោយកំលាំងចិត្ត

ខ្ញុំហើយ ខ្ញុំនឹកណាស់ ។ខ្ញុំបានជួលផ្ទះគេស្នាក់នៅហើយក៏បន្តដើររកការងារធ្វើបន្តទៀត ។
ខ្ញុំមិនមានការងារពិតប្រាកដ ជាប់លាប់ទេ គឺធ្វើនេះបន្តិច ធ្វើនោះបន្តិចអោយតែមាននិងដើម្បីរស់ ។
ថ្ងៃមួយខ្ញុំបានជួបនិង មិត្តភក្តិម្នាក់ ហើយគាត់ក៏អោយយោបល់ខ្ញុំអោយខ្ញុំរៀនរកស៊ីដោយខ្លួនឯង ។
ខ្ញុំបានគិតពិចារណាហើយក៏សំរេចចិត្តយកម៉ូតូទៅលក់ ហើយទិញម៉ូតូដែលមានតំលៃថោកជាងសំរាប់ជិះវិញ ។ ខ្ញុំសំរេចចិត្តជួលផ្ទះគេតូចមួយ សំរាប់បើករកស៊ី ពេលនោះខ្ញុំពិតជាក្លាហានណាស់ដែលនៅក្នុងខ្លួនមានប្រាក់តែ២៥០ដុល្លា តែខ្ញុំហ៊ានបើកក្រុមហ៊ុនមួយ ។ពាក្យថាក្រុមហ៊ុនទោះជាតូចប៉ុណ្ណាក៏ត្រូវការប្រាក់ដែរ ខ្ញុំត្រូវបានមិត្តម្នាក់អោយ តុ ខ្ញុំមួយសំរាប់អង្គុយធ្វើការ មានមិត្តបរទេសម្នាក់អោយទូរស័ព្ទមួយគ្រឿង ។ ខ្ញុំបានរៀបចំអោយមានរបៀបរៀបរយល្អ ពីព្រោះខ្ញុំមានបទពិសោធន៏ខ្លះៗដែលធ្លាប់ធ្វើការកន្លងមក ។ ខ្ញុំត្រូវប្រើរយះពេលជិត២ខែទើបរៀបចំអោយក្រុមហ៊ុនមានរបៀបរៀបរយហើយក៏ដល់ពេលវេលាដែលប្រាក់សន្សំត្រូវអស់ ។ ក្រុមហ៊ុនរបស់ខ្ញុំមានបុគ្គលិកតែ២នាក់ប៉ុណ្ណោះប៉ុន្តែខ្ញុំស្ទើរតែគ្មានប្រាក់ខែបើកអោយពួកគេ ខ្ញុំចាប់ផ្តើមក្លាយជាមនុស្សចេះខ្ចីប្រាក់គេដើម្បីដោះស្រាយបញ្ហា ។
ក្រុមហ៊ុនរបស់ខ្ញុំរកប្រាក់ចំណូលបានសំរាប់តែផ្គត់ផ្គង់បុគ្គលិកឈ្នួលផ្ទះ និងបញ្ហាផ្សេងៗទៀតជាច្រើន ។
បំណុលកាន់តែច្រើន ការប្រាក់កាន់តែខ្ពស់ខ្ញុំត្រូវប្រឹងរកស៊ីដោយគ្មានថ្ងៃសៅរ៍ឬអាទិត្យទេ ។
ខ្ញុំបានលក់ម៉ូតូ ហើយជួលឡានគេជិះ ។ ខ្ញុំមិនមែនជាមនុស្សដែលត្រេកត្រអាលនិងរថយន្តអីទេតែវាជាតំរូវការសំរាប់ក្រុមហ៊ុនហើយខ្ញុំមិនមានលទ្ធិភាពទិញ ។
ខ្ញុំកាន់តែយ៉ាប់ទៅៗ បំណុលសឹងតែលិចក្បាលខ្ញុំ ។ ខ្ញុំមិនរៀបរាប់ពីបញ្ហានេះទៀតទេព្រោះវាវែងឆ្ងាយណាស់ ។ ដឹងតែម្យ៉ាង គឺត្រូវរកដំណោះស្រាយ ដើម្បីទប់ស្កាត់បញ្ហានេះ ។ ហ៊ឺ ខ្ញុំអស់សង្ឃឹមកាន់តែខ្លាំងខ្ញុំអស់លទ្ធិភាពហើយ ខ្ញុំគិតថាខ្ញុំត្រូវតែរត់ទៅអោយឆ្ងាយដើម្បីគេចចេញពីបញ្ហា ។
តែខ្ញុំមិនអាចធ្វើបានពីព្រោះវាក្បត់និងឧត្តមគតិរបស់ខ្ញុំ គិតហើយខ្ញុំសច្ចាថាខ្ញុំនឹងតស៊ូតទៅទៀតដ៏រាបណាខ្ញុំនៅមានជីវិតខ្ញុំត្រូវតែមានសង្ឃឹម ។ ក្នុងកំឡុងឆ្នាំ២០០០ដែលខ្ញុំកំពុងតែទទួលរងរឿងរ៉ាវមិនចេះចប់មិនចេះហើយវាសនាបានកំណត់អោយខ្ញុំបានស្គាល់នារីម្នាក់ដែលនាងជាកូនអ្នកក្រីក្រដូចជាខ្ញុំដែរហើយមានស្រុកកំណើតនៅភាគខាងកើតនៃទីក្រុងភ្នំពេញតែនាងបានមករស់នៅភ្នំពេញជាមួយម្តាយដែលជាស្ត្រីមេម៉ាយមានកូនក្នុងបន្ទុក៤នាក់ហើយគាត់មានមុខរបរជាអ្នកលក់ដូរបន្តិចបន្តួចនៅផ្សារ ។
នាងជានារីម្នាក់ដែលមានអត្តចរិកស្លូតបូតគួរអោយគោរពស្រលាញ់ហើយជានារីដែលឧស្សាហ៏ព្យាយាម ។

លើលោកនេះគ្មានអ្នកណាដែលមិនត្រូវការសេចក្តីស្នេហានោះទេ គ្រាន់តែពេលវេលាមិនទាន់ដល់តែប៉ុណ្ណោះ ។ខ្ញុំមិនមែនជាមនុស្សដែលមានបេះដូងដែកទេខ្ញុំក៏ត្រូវការមនុស្សដែលខ្ញុំស្រលាញ់ដើម្បីជាកំលាំងចិត្តដែរ ។

ហើយយើងទាំងពីរនាក់បានស្វែងយល់ចិត្តគ្នារយះពេលកន្លះឆ្នាំហើយក៏សំរេចចិត្តរៀបការក្នុងថ្ងៃទី ០៣ ខែមករា ឆ្នាំ២០០១ ។ នាងមិនបានដឹងឡើយថាខ្ញុំកំពុងជួបនូវផលលំបាកអ្វីខ្លះ ព្រោះខ្ញុំព្យាយាមលាក់នាងរហូត ។ នៅថ្ងៃយើងរៀបការមានម្ចាស់បំណុលម្នាក់គាត់មិនបានយោគយល់ទេ គឺគាត់បានទៅតាមទារប្រាក់ខ្ញុំដល់ផ្ទះភរិយាខ្ញុំ តែគាត់មិនបានបញ្ចេញប្រតិកម្មទេ ។គ្រាន់តែឃើញគាត់ភ្លាមខ្ញុំបានស្ទុះទៅសំពះអង្វរគាត់ថា សូមអោយគាត់មេត្តាទុកពេលអោយយើងរៀបការរួចសិន ។ ដោយការអង្វរកខ្លាំងពេកគាត់ក៏បានត្រឡប់ទៅវិញ ។ រៀបការបាន៣ថ្ងៃខ្ញុំនិងភរិយាបានសំពះលាអ្នកម្តាយនិងញាតិមិត្ត បង ប្អូនត្រឡប់មកភ្នំពេញវិញ ។ មកដល់ភ្នំពេញខ្ញុំសំរេចចិត្តជួលផ្ទះគេមួយទៀតដែលនៅជាន់ទី២សំរាប់ស្នាក់នៅជាមួយភរិយាដែលមានតំលៃ៤០ដុល្លា ។ ខ្ញុំចាប់ផ្តើមចូលធ្វើការក្រុមហ៊ុនឡើងវិញ ភរិយាខ្ញុំនាងមានប្រាក់ខ្លះនៅសល់ពីការសន្សំ ហើយនាងមិនហ៊ានចាយវាយទេ គឺនាងរក្សាទុកតែប្រាក់នោះមិនច្រើនទេ ។ម្តាយក្មេករបស់ខ្ញុំគាត់បានត្រឡប់មកភ្នំពេញវិញ ។ មិនដឹងថាត្រូវយំឬត្រូវសើចទេនៅពេលនេះពីព្រោះផ្ទះដែលជួលនោះគេគ្មានដាក់សំភារះអោយយើងទេ ។ ភរិយាខ្ញុំបានយកប្រាក់ទៅទិញកន្ទេលមួយ ខ្នើយពីរ និងភួយមួយសំរាប់សំរាកបណ្តោះអាសន្ន ។ យើងតែងតែក្រាលកន្ទេលសំរាកនៅនិងឥដ្ឋហើយស្ទើតែរាល់ពេលព្រឹកភរិយារបស់ខ្ញុំបានបបរនិងចៀនពងទា អោយខ្ញុំទទួលទានមុនពេលចេញទៅធ្វើការ ។ ឆ្លៀតពេលទំនេរពីកិច្ចការផ្ទះនាងបានទៅជួបម្តាយនាងដែលគាត់ជួលផ្ទះគេតូចមួយក្បែររោងចក្រកាត់ដេរមួយកន្លែងនៅស្ទឹងមានជ័យ ។ ខ្ញុំមិនដឹងថានាងទៅនិយាយអ្វីជាមួយម្តាយរបស់នាងទេស្រាប់តែល្ងាចឡើងអ្នកម្តាយក្មេករបស់ខ្ញុំគាត់បានដឹកគ្រែឈើចាស់មួយដែលគាត់ធ្លាប់តែសំរាន្តទូរទស្សន៍តូចមួយដែលគាត់ធ្លាប់មើលនិងមានចានក្បានខ្លះទៀតយកមកអោយពួកយើង ។

ខ្ញុំសែនរន្ធត់ចិត្តឥតឧបមា ដែលខ្ញុំមានមាតាដែលមានចិត្តសប្បុរសបែបនេះខ្ញុំសួរគាត់ថា:ម៉ែ ៗយកវាមកធ្វើអី? គាត់ឆ្លើយថាម៉ែគ្មានអីអោយកូនទេ គឺម៉ែមានតែប៉ុណ្ណឹងទេកូនទុកប្រើសិនចុះ ។

យើងទាំងបីរនាក់យំទល់មុខគ្នាហួសចិត្តនិងព្រហ្មលិខិតដែលនៅតែតាមធ្វើបាបព្យាបាទពួកយើងគ្រប់ពេលវេលា ។ទឹកចិត្តរបស់អ្នកម្តាយក្មេកខ្ញុំក៏មិនខុសពីលោក ឪពុក អ្នកម្តាយរបស់អ្នកទាំងអស់គ្នាដែល

គាត់និងធ្វើគ្រប់យ៉ាងដើម្បីអោយអ្នកបានសេចក្ដីសុខ ។ ខ្ញុំនៅតែព្យាយាមលាក់រឿងដែលខ្ញុំជំពាក់គេមិនអោយភរិយារបស់ខ្ញុំដឹងឡើយ ។ ប៉ុន្តែនាងបានដឹងរួចទៅហើយតែនាងធ្វើដូចជាមិនបានដឹងរឿងអ្វីទាំងអស់ ។អ្នកជឿទេក្នុងផ្ទះរបស់ខ្ញុំមិនដែលមានប្រាក់លើស ពី៣០ដុល្លាឡើយគឺមានតែទាបជាងនេះ ។ នេះឬជាប្រធានក្រុមហ៊ុន?

ដោយសារតែជីវិតជួបតែភាពលំបាកលំបិនគេចមុខគេចក្រោយពីម្ចាស់បំណុលខ្ញុំក៏ដាច់ចិត្តរៀបរាប់នូវរឿងរ៉ាវទាំងអស់អោយភរិយាខ្ញុំស្ដាប់ ហើយខ្ញុំសួរនាងថា: បើខ្ញុំគ្មានប្រាក់តើនាងស្អប់ខ្ញុំទេ?

នាងបានស្រវ៉ាអោបខ្ញុំដោយ មិនមាននិយាយអ្វីមួយម៉ាត់នាងបានសម្រក់ទឹកភ្នែកទាំងទឹកមុខញញឹមនឹងបង្កប់ដោយក្ដីស្រណោះខ្លួនដែលនាងមានស្វាមីជាកូនកំព្រានិងក្រលំបាកទៀតតែនាងនៅតែស្រលាញ់និងគោរពខ្ញុំ ។បានប្រមាណ៥ថ្ងៃក្រោយពេលដែលខ្ញុំបាននិយាយប្រាប់នាងខ្ញុំបានឃើញនាងជិះម៉ូតូឌុបក្រោមតំណក់ទឹកភ្លៀងសស្រិចយំបណ្ដើរជូតទឹកភ្នែកបណ្ដើរ ហើយខ្ញុំបានបើករថយន្តដែលជួលគេជិះនោះជិះពីក្រោយនាងរហូត ។ ប្រហែលជាប្រាំនាទីនាងបានមកឈប់នៅផ្សារដើមគហើយដើរសំដៅទៅតូបលក់មាសមួយ ។ ខ្ញុំមិនដឹងថានាងធ្វើអ្វីទេ គឺបានត្រឹមតែមើលពីចំងាយ មួយសន្ទុះនាងក៏ត្រឡប់ទៅផ្ទះវិញ ។ ល្ងាចឡើងពេលដែលខ្ញុំត្រឡប់ពីធ្វើការវិញបន្ទាប់ពីហូបបាយល្ងាចរួចភរិយារបស់ខ្ញុំបានយកប្រាក់ចំនួន៥៨០ដុល្លាមកអោយខ្ញុំ ។ហើយនាងប្រាប់ថានេះជាប្រាក់ដែលបានពីការលក់របស់ខ្លះៗពីការសន្សំជាយូមកហើយរបស់នាងអោយមកខ្ញុំ ហើយនាងនិយាយថា:

បងយកទៅសងបំណុលគេចុះ ខ្ញុំអាណិតភរិយារបស់ខ្ញុំស្ទើរខ្លោចចិត្តដែលនាងធ្វើគ្រប់យ៉ាងដើម្បីស្វាមី លើលោកនេះខ្ញុំនៅមានមនុស្សដែលយល់ចិត្តខ្ញុំ ដែលស្រលាញ់និងធ្វើអ្វីៗដើម្បីខ្ញុំ ។

ដូច្នេះហើយទើបអត្ថបទវគ្គបីខ្ញុំបានរៀបរាប់ពីទឹកចិត្តដ៏សែនប្រពៃរបស់ភរិយា ។ ខ្ញុំក្រតែខ្ញុំសប្បាយចិត្តគ្រប់ពេលខ្ញុំតែងតែបានការលើកកំលាំងចិត្តពីភរិយាខ្ញុំជានិច្ច ។ ហើយខ្ញុំក៏កាន់តែមានទឹកចិត្តក្នុងការធ្វើការងារ ។ អ្នកដឹងទេមានពេលមួយភរិយារបស់ខ្ញុំគាត់បានហាលសំលៀកបំពាក់និងភួយហើយគាត់ទៅផ្សារពេលដែលត្រឡប់មកវិញ ក៏ត្រូវចោរលួចអស់គ្មានសល់ ។ គាត់អង្គុយយំរហូតដល់ពេលដែលខ្ញុំមកដល់ផ្ទះ គាត់ស្ដាយសំលៀកបំពាក់ស្ដាយភួយហើយអ្វីដែលសំខាន់នោះគឺពួកយើងគ្មានប្រាក់ទិញវា ។ ល្ងាចនោះពេលទទួលទានអាហារខ្ញុំចាំបានថាពួកយើងទទួលទានអាហារបណ្ដើរ សម្រក់ទឹកភ្នែកដាក់ចានបាយបណ្ដើរ តែពួកយើងខំប្រឹងញញឹមដើម្បីបំភ្លេចទុក្ខ ។

ពេលយប់មកដល់យើងគ្មានភួយដណ្ដប់ទេយើងបានដណ្ដប់មុងហើយខ្ញុំស្រម័យថាជីវិតរបស់ខ្ញុំពេលនេះ មិនខុសពីកុមារភាពឡើយហើយគឺខ្ញុំថែមទាំងផ្ដល់នូវផលលំបាកដល់ភរិយាខ្ញុំទៀតផង ។ដោយសារតែ មើលឃើញជីវភាពរបស់កូនកាន់តែលំបាកម្ដាយក្មេករបស់ខ្ញុំគាត់បានទៅចងការប្រាក់គេយកមកអោយ កូនដើម្បី បានដោះស្រាយបញ្ហា ។ ភរិយារបស់ខ្ញុំគាត់ក៏បានសំរេចចិត្តចូលមកធ្វើការនៅក្រុមហ៊ុនដើម្បី ជួយមើលការខុសត្រូវខ្លះៗ ។ យើងទាំងពីរនាក់តស៊ូ មិនហ៊ានហូបអាហារឆ្ងាញ់ មិនហ៊ានទិញសំលៀក បំពាក់ថ្មីទេ ពីព្រោះយើងត្រូវការសន្សំប្រាក់ដើម្បីរំលោះបំណុល ។

យើងបានសច្ចាជាមួយគ្នាថានឹងប្រឹងប្រែងរហូតដល់ទីបញ្ចប់ទោះជាយើងត្រូវស្លាប់គឺស្លាប់ជាមួយគ្នា ។ វាជាការពិតទោះជាយើងក្រ យើងលំបាកតែពួកយើងមិនដែលមានជំលោះណាមួយធ្វើអោយសង្គម គ្រួសារដ៏តូចរបស់យើងមានបញ្ហានោះទេ ។ ខ្ញុំចង់បញ្ជាក់ថាជំលោះមិន ធ្វើអោយអ្នកទទួលបានជោគ ជ័យឡើយ ជាពិសេសគឺជំលោះរវាងក្រុមគ្រួសារ ។ គឺមានតែការ តស៊ូ ស្មោះត្រង់ អំណត់ព្យាយាម យល់អធ្យាស្រ័យការយល់ចិត្តគ្នានិងផ្ដល់កំលាំងចិត្តអោយគ្នាជាទង្វើសំរាប់ឆ្ពោះទៅរកភាពជោគជ័យ ។ ទេវតាមិនមែនគ្មានភ្នែករហូតនោះទេ ការតស៊ូរបស់យើង បានទទួលជោគជ័យជាបណ្ដើរៗ ក្រុមហ៊ុន របស់ខ្ញុំបានទទួលយកនូវបុគ្គលិកបន្ថែមទៀតហើយបានប្រាក់ចំណូលខ្លះៗ ខ្ញុំយកទៅសងគេរំលោះ បន្តិចម្ដងៗ ។ ហើយខ្ញុំនិងភរិយាកាន់តែព្យាយាមប្រឹងប្រែងមិនអោយមានពេលទំនេរសោះឡើយ ។ ប្រមាណ៣ឆ្នាំបន្ទាប់សេចក្ដីព្យាយាមរបស់ពួកយើងជិតបានសំរេច ។

យើងរកប្រាក់បានប៉ុន្មានយើងបន្តសងគេខ្លះៗរហូតរួចនូវបំណុលជាច្រើនលើសលប់គឺរហូតដល់រាប់ម៉ឺន ដុល្លា ដែលអ្នកបានស្គាល់ខ្ញុំគេគិតថាខ្ញុំមិនអាចធ្វើទៅរួចទេ តែសំរាប់ពួកយើង គឺអាចធ្វើទៅបាន ។ ដូចនេះខ្ញុំសូមអោយប្អូនៗ ជំនាន់ក្រោយធ្វើការតស៊ូ អំណត់អត់ធន់ ជាពិសេសបំផុត គឺអ្នកត្រូវតែជា មនុស្សស្មោះត្រង់ចំពោះខ្លួនឯង និងអ្នកដ៏ទៃ ។

មកដល់ពេលនេះខ្ញុំបានក្លាយជាមនុស្សម្នាក់ដែលមានជីវភាព រស់នៅសមរម្យ មានក្រុមគ្រួសារដែល កក់ក្ដៅពិសេសពួកយើងទទួលបាននូវចំណងដៃកូនប្រុសសំលាញ់ដល់ទៅ៣នាក់ ហើយ ខ្ញុំមានជីដូនមាន ម្ដាយ មានបងប្អូន ហើយក្រុមហ៊ុន ដែលពីមុនជាក្រុមហ៊ុនដ៏សែនកំសត់តូចមួយ ឥឡូវបានប្រែក្លាយជា ក្រុមហ៊ុនដែលមានបុគ្គលិកយ៉ាងច្រើន ជាពិសេសគឺអ្វីដែលពួកយើងមិនធ្លាប់មានយើងមាននៅពេលនេះ ដល់ពេលវេលាហើយដែលខ្ញុំត្រូវជំរាបពុកម៉ែ និង ប្រិយមិត្តអ្នកស្ដាប់ថា**ខ្ញុំជាអ្នកណា** ។

គឺខ្ញុំមានឈ្មោះ **ស៊ឹង ប៊ុណ្ណា** និង ភរិយា របស់ខ្ញុំ ឈ្មោះ **សន សុម៉ាលី** ហើយជានាយកនៃក្រុមហ៊ុន **ប៊ុណ្ណា រៀលធីគ្រុប** និង **ខ្មែរ ប៊ីយូធី** និងជាម្ចាស់ដែលបានរៀបចំនិងបង្កើតនូវកម្មវិធី **កូនខ្មែរពិត** នេះឡើង ហើយខ្ញុំគិតថាអ្នកទាំងអស់គ្នាពិតជាមិនសើច យំ និងខ្ញុំទេ ដែលខ្ញុំបានសរសេរនូវអត្ថបទនេះឡើង ។

ជាចុងបញ្ចប់ខ្ញុំបាទសូមគោរពថ្លែងនូវអំណរអគុណចំពោះ ពុក ម៉ែដែលបានផ្តល់កំណើតអោយកូន ទោះបីជាខ្ញុំមិនបានស្គាល់លោកទាំងពីរក៏ដោយ អគុណលោកតា លោកយាយ អ្នកម្តាយក្មេក ពូមីង លោកគ្រូ អ្នកគ្រូ បុគ្គលិកទាំងអស់ ជាពិសេសបុគ្គលិកដែលបានតស៊ូជាមួយគ្នាតាំងពីពួកយើងមាន តែបាតដៃទទេហើយសូមអគុណដល់មជ្ឍមណ្ឌលកុមារកំព្រាមួយកន្លែងដែលខ្ញុំធ្លាប់បានស្នាក់នៅហើយ ដែលកន្លងមកខ្ញុំមិនបានរៀបរាប់ប្រាប់អ្នកទាំងអស់ មួយវិញទៀតខ្ញុំក៏មិនភ្លេចពីគុណបំណាច់លោកអ្នក ដែលបានផ្តល់ទីជំរកអោយខ្ញុំបានស្នាក់នៅគ្រប់ទីកន្លែង និងអ្នកដែលបានផ្តល់នូវប្រាក់សំរាប់អោយខ្ញុំ បានខ្ចី ខ្ញុំគ្មានអ្វីតបស្នងសងគុណអ្នកទាំងអស់គ្នាទេ គឺមានតែលើកម្រាមដៃដប់សំពះអរគុណអ្នកទាំង អស់ពីចំងាយ ។

ហើយនិងជាចុងក្រោយអគុណចំពោះលោកអ្នកដែលនិយមគាំទ្រនូវកម្មវិធីនេះ និងពិសេសបំផុត នោះគឺចំពោះអ្នកនាងពិធីការិនី ដែលខ្ញុំបានធ្វើអោយអ្នកលំបាក ប្រសិនបើមានកំហុសខុសឆ្គងសូមអ្នក ទាំងអស់គ្នាមេត្តាយល់អធ្យាស្រ័យអោយខ្ញុំបាទផងពីព្រោះខ្ញុំគ្មានជំនាញនិងចំណេះដឹងផ្នែកនេះទេ ។ ខ្ញុំចង់បញ្ជាក់ជាចុងក្រោយថានេះហើយជាបទពិសោធន៍សំរាប់ជីវិតរបស់ខ្ញុំ ។ហើយគោលបំណងធំរបស់ខ្ញុំ ដែលបង្កើតកម្មវិធី**កូនខ្មែរពិត**នេះឡើង គឺខ្ញុំចង់អោយអ្នកដែលជួបនូវបញ្ហាដូចខ្ញុំ ឬ ក៏លំបាក ជាងខ្ញុំ ជាពិសេសជនអនាថា និងក្មេងកំព្រាទាំងឡាយ សូមអ្នក តស៊ូ ព្យាយាម អត់ធ្មត់ ស្មោះត្រង់ បើអ្នកដួល អ្នកត្រូវងើបឈរ អ្នកកុំចុះចាញ់ និងព្រហ្មលិខិតអោយសោះ ដរាបណាអ្នកនៅមានជីវិតអ្នកត្រូវតែ ប្រឹងប្រែង ប្រែក្លាយខ្លួនរបស់អ្នក អោយក្លាយជាអ្នកដែលទទួលបានជោគជ័យសំរាប់ថ្ងៃខាងមុខ ។

អ្នកត្រូវចងចាំនូវសុភាសិតមួយឃ្លាថា **អតីតកាលជូរចត់ បច្ចុប្បន្នស៊ូហត់ អនាគតរុងរឿង ។**

ខ្ញុំបាទសូមលំអោនកាយជំរាបលាអ្នកទាំងអស់គ្នាដោយក្តីរាប់អាន និងអាលោះអាល័យបំផុត

ភ្នំពេញថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០០៨

**ពីខ្ញុំបាទ ស៊ឹង ប៊ុណ្ណា**